**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ ១០០៨ សជណ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីវិធានការគ្រប់គ្រងបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ។

**យោង** ៖ សេចក្តីណែនាំលេខ ០០៣ សណន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** ជ្រាបថា ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃជំងឺកូវីដ១៩ នៅក្នុងប្រទេសថៃ រាជរដ្ឋាភិបាលថៃបានប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្នចាប់ពីថ្ងៃទី២៦ ខែមីនា ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។ ជាមួយនេះ រាជរដ្ឋាភិបាលថៃបានសម្រេចបិទច្រកទ្វារព្រំដែនគោកទាំងអស់រវាងកម្ពុជានិងថៃ ដោយមិនអនុញ្ញាតឲ្យអ្នកដំណើរចេញចូលឆ្លងកាត់ព្រំដែនរវាងប្រទេសទាំងពីរជាបណ្តោះអាសន្ន ដែលបានអនុវត្តចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ លើកលែងតែរថយន្តដឹកទំនិញ។ ក្នុងស្ថានភាពខាងលើនេះ ប្រជាពលរដ្ឋខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃបានធ្វើដំណើរវិលត្រលប់ចូលមកក្នុងប្រទេសកម្ពុជាវិញជាបន្តបន្ទាប់។

ដើម្បីពង្រឹងការគ្រប់គ្រង ការសម្របសម្រួល និងការត្រួតពិនិត្យសុខភាពប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃចូលមកប្រទេសកម្ពុជាតាមច្រកទ្វារព្រំដែនគោកកម្ពុជា-ថៃឲ្យបានហ្មត់ចត់ សំដៅចូលរួមបង្ការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ នៅកម្ពុជា ក្រសួងមហាផ្ទៃស្នើ **ឯកឧត្តម លោកជំទាវ** ចាត់ចែងអនុវត្តនូវវិធានការនានា ដូចខាងក្រោម៖

**ក. សម្រាប់រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ**

- បង្កើតក្រុមការងារមួយដើម្បីទទួលខុសត្រូវសម្របសម្រួល និងដឹកនាំការងារទទួលប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ ដោយចាត់តាំងអភិបាលរងខេត្ត ០១រូប ជាប្រធាន និងមានការចូលរួមពីអភិបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់ កងកម្លាំងប្រដាប់អាវុធ និងមន្ទីរអង្គភាពពាក់ព័ន្ធតាមការចាំបាច់
- ក្រុមការងារនេះត្រូវធ្វើការទំនាក់ទំនង និងជួបពិភាក្សាជាមួយអាជ្ញាធរខេត្ត និងកងកម្លាំងមានសមត្ថកិច្ចនៃប្រទេសថៃ ដើម្បីសម្របសម្រួលដល់ប្រជាពលរដ្ឋខ្មែរដែលបានវិលត្រលប់ចូលមកក្នុងប្រទេសកម្ពុជាវិញតាមច្រកទ្វារព្រំដែនគោកកម្ពុជា-ថៃ សំដៅធានាឲ្យបាននូវរបៀបរៀបរយ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនៅក្នុងការធ្វើដំណើរចេញចូលឆ្លងកាត់ព្រំដែន និងបង្ការទប់ស្កាត់ការីករាលដាលនៃជំងឺកូវីដ១៩ នៅកម្ពុជា។ ចំពោះ

ការងារនេះ ត្រូវចាត់ឲ្យមានមន្ត្រីប្រចាំការសម្រាប់ទំនាក់ទំនងគ្នាជាមួយមន្ត្រី ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសថៃ ដើម្បីក្តាប់បានច្បាស់លាស់នូវស្ថិតិ និងស្ថានភាពនៃការវិលត្រលប់ចូលក្នុងប្រទេសវិញរបស់បងប្អូនប្រជាពលរដ្ឋខ្មែរ

- ត្រូវសហការជាមួយសមត្ថកិច្ចប្រចាំច្រកទ្វារព្រំដែន ដើម្បីអនុវត្តវិធានចត្តាឡីស័កក្នុងការត្រួតពិនិត្យសុខភាព និងគ្រប់គ្រងប្រជាពលរដ្ឋខ្មែរដែលឆ្លងដែនចូលមកប្រទេសកម្ពុជាតាមច្រកទ្វារព្រំដែនគោកកម្ពុជា-ថៃ ឲ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងមានសុវត្ថិភាពល្អ។ ទន្ទឹមនេះ ត្រូវណែនាំពួកគាត់អំពីវិធានការបង្ការ ទប់ស្កាត់ការឆ្លងជំងឺកូវីដ១៩ ក្នុងអំឡុងពេលស្នាក់នៅបណ្តោះអាសន្ននៅតំបន់ព្រំដែន និងអំឡុងពេលធ្វើដំណើរទៅកាន់លំនៅឋានរៀងៗខ្លួន ព្រមទាំងណែនាំឲ្យពួកគាត់ទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ស្របតាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល
- ត្រូវត្រៀមរៀបចំកន្លែងស្នាក់នៅបណ្តោះអាសន្ន ស្បៀង គ្រឿងឧបភោគបរិភោគ ថ្នាំពេទ្យ និងបុគ្គលិកពេទ្យ ដើម្បីជួយឧបត្ថម្ភគាំទ្រ និងថែទាំសុខភាពបងប្អូនប្រជាពលរដ្ឋក្នុងរយៈពេលដែលពួកគាត់ស្នាក់នៅបណ្តោះអាសន្ននៅតំបន់ព្រំដែន ដើម្បីរង់ចាំវិលត្រលប់ទៅលំនៅឋានរៀងៗខ្លួន ជាពិសេសត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះកុមារ ទារក ស្ត្រីមានផ្ទៃពោះ និងអ្នកមានជំងឺ។ ជាមួយនេះ ត្រូវចាត់ចែងកម្លាំងធានាការពារសុវត្ថិភាព និងទ្រព្យសម្បត្តិរបស់ពួកគាត់ផងដែរ
- ត្រូវស្រង់ស្ថិតិបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកវិញ និងផ្តល់ព័ត៌មានជូនដល់រដ្ឋបាលរាជធានី ខេត្តពាក់ព័ន្ធ ដើម្បីចូលរួមសហការចាត់ចែងមកទទួលដឹកជញ្ជូនពួកគាត់វិលត្រលប់ទៅកាន់លំនៅឋានរៀងៗខ្លួននៅតាមរាជធានី ខេត្ត ប្រកបដោយសុវត្ថិភាព។

**ខ. <u>សម្រាប់រដ្ឋបាលរាជធានី ខេត្តទាំងអស់</u>**

- បង្កើតក្រុមការងារមួយដើម្បីទទួលខុសត្រូវទទួល និងដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់ពីប្រទេសថៃ ដោយចាត់តាំងអភិបាលរងរាជធានី ខេត្ត ០១រូប ជាប្រធាន និងមានការចូលរួមពីអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ កងកម្លាំងប្រដាប់អាវុធ និងមន្ទីរ អង្គភាពពាក់ព័ន្ធតាមការចាំបាច់(លើកលែងរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃដែលបានបង្កើតរួចហើយតាមស្មារតីចំណុច ក ខាងលើ)
- ត្រូវទំនាក់ទំនង និងចូលរួមសហការជាមួយរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីជួយឧបត្ថម្ភដោះស្រាយដល់ការដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ពីព្រំដែនទៅកាន់លំនៅឋានរបស់ពួកគាត់
- ត្រូវចាត់ចែងមធ្យោបាយសមស្រប ដើម្បីជួយដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរពីព្រំដែនទៅកាន់លំនៅឋានរបស់ពួកគាត់ រួមទាំងជួយឧបត្ថម្ភនូវម្ហូបអាហារ ទឹក សម្ភារ និងថ្នាំពេទ្យ
- ក្នុងការដឹកជញ្ជូនបងប្អូនប្រជាពលរដ្ឋខ្មែរនេះ ត្រូវយកចិត្តទុកដាក់អំពីសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់ពួកគាត់ ព្រមទាំងត្រូវរក្សាឲ្យបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ

- អាចធ្វើការអំពាវនាវដល់សប្បុរសជនឲ្យជួយឧបត្ថម្ភដោយស្ម័គ្រចិត្តនូវថវិកា សម្ភារ គ្រឿងឧបភោគបរិភោគ ថ្នាំពេទ្យ និងមធ្យោបាយដឹកជញ្ជូន ដើម្បីចូលរួមចំណែកដោះស្រាយការលំបាកនានារបស់បងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ
- ត្រូវណែនាំដល់អាជ្ញាធរឃុំ សង្កាត់ ភូមិ ឲ្យចុះតាមផ្ទះប្រជាពលរដ្ឋដែលទើបវិលត្រលប់មកពីប្រទេសថៃ ដើម្បីអប់រំណែនាំដល់ពួកគាត់ឲ្យអនុវត្តវិធានការដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ ស្របតាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល ព្រមទាំងធ្វើការណែនាំដល់ក្រុមគ្រួសារអំពីវិធានការការពារការឆ្លងជំងឺកូវីដ១៩
- ត្រូវណែនាំដល់អាជ្ញាធរឃុំ សង្កាត់ ភូមិ ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃ អនុវត្តវិធានការដាក់ខ្លួនឲ្យនៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃ បានត្រឹមត្រូវតាមនីតិវិធីដែលបានកំណត់។ ក្នុងនោះ អាជ្ញាធរក្រុង ស្រុក ខណ្ឌ ត្រូវតាមដាន និងជួយគាំទ្រដល់អាជ្ញាធរឃុំ សង្កាត់ ភូមិ នៅក្នុងការចាត់ចែងអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាពខ្ពស់
- ត្រូវណែនាំដល់អាជ្ញាធរក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ឲ្យសហការគ្នាបង្កើនសកម្មភាពបិទផ្សាយផ្ទាំងរូបភាព និងចាក់មេក្រូផ្សព្វផ្សាយសារសម្លេងអប់រំរបស់គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ ដើម្បីប្រជាពលរដ្ឋទាំងអស់បានជ្រាប និងចូលរួមបង្ការទប់ស្កាត់ជំងឺកូវីដ១៩ នៅមូលដ្ឋានរៀងៗខ្លួន ជាពិសេសភូមិ ឃុំ សង្កាត់ ដែលមានបងប្អូនប្រជាពលរដ្ឋច្រើនទើបវិលត្រលប់មកពីប្រទេសថៃ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** ជ្រាប និងចាត់ចែងអនុវត្តតាមខ្លឹមសារខាងលើ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវសេចក្តីរាប់អានពីខ្ញុំ៕

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ